# Fair Trial Principle

# គោលការណ៍កាត់ក្តីដោយយុត្តិធម៌

## សេចក្តីផ្តើម

យោងតាមលទ្ធផលនៃការស្ទាបស្ទង់មតិកាលពី ខែសីហា ឆ្នាំ២០០៤ របស់វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ ស្តីពីសម័យខ្មែរក្រហម និងសាលាជំរះក្តីកាត់ទោសខ្មែរក្រហម យើងឃើញថា ៦១,៣% នៃប្រជាពលរដ្ឋកម្ពុជាចំនួន ៥៣៦នាក់ មានការរំពឹងទុកថា តុលាការកាត់ទោសខ្មែរក្រហមដែលនឹងបង្កើតឡើងនៅពេលខាងមុខនេះ នឹងនាំមកនូវយុត្តិធម៌ ។

ជាទូទៅ ការកាត់ក្តីមួយអាចប្រព្រឹត្តទៅបានដោយយុត្តិធម៌ គឺអាស្រ័យទៅលើកត្តាច្រើនយ៉ាង ដូចជា រចនាសម្ព័ន្ធនៃតុលាការ ដំណើរការជ្រើសរើសចៅក្រម និងបុគ្គលិកតុលាការប្រព្រឹត្តទៅប្រកបដោយតម្លាភាព ជាពិសេស ការអនុវត្តន៍នីតិវិធី ត្រូវតែស្របទៅនឹងគោលការណ៍កាត់ក្តីដោយយុត្តិធម៌ ។

ម្យ៉ាងទៀត ការជំនុំជំរះប្រកបដោយយុត្តិធម៌នេះ ត្រូវតែគោរព និងផ្តល់ដល់បុគ្គលគ្រប់រូបនូវ **សិទ្ធិស្មើគ្នាចំពោះមុខច្បាប់**[១] ដោយការប្រព្រឹត្តចំពោះ សាក្សី និងជនល្មើស តាមវិធីដូចៗគ្នា ។ នេះមានន័យថា យើងត្រូវផ្តល់ឱ្យភាគីក្តីទាំងពីរនូវឱកាសដូចគ្នា ដើម្បីបង្ហាញនូវសិទ្ធិក្នុងការការពាររឿងក្តីរបស់ខ្លួន និងការប្រាស្រ័យទាក់ទងជាមួយតួអង្គដទៃទៀត នៅក្នុងនីតិវិធីនានាប្រកបដោយតម្លាភាព ។ លើសពីនេះទៀត នីតិវិធីជំនុំជំរះ "ដោយយុត្តិធម៌" ក៏ត្រូវធានាផងដែរនូវការគោរពសិទ្ធិរបស់គូភាគីដែលត្រូវរួចផុតពី **ការបង្ខិតបង្ខំ ឬការធ្វើបាប** និងការគោរពគោលការណ៍សំខាន់ៗមួយចំនួន ដូចជា **ការហាមប្រាមលើការដាក់ទណ្ឌកម្ម ឬការដាក់ទោសដែលមិនសមាមាត្រ** ។ ជាចុងក្រោយ ការជំនុំជំរះនេះ ក៏ត្រូវតែផ្តល់នូវដំណោះស្រាយ និងយុត្តិធម៌ **មិនលឿនពេក ហើយក៏មិនយូរពេក** គឺត្រូវមានការរៀបចំនីតិវិធីមួយដោយមានរយៈពេលសមស្រប ដើម្បីឱ្យគូភាគីទាំងពីរអាចនឹងរៀបចំ និងបង្ហាញពីភស្តុតាង និងសាក្សីនានា របស់ពួកគេ ។

យើងត្រូវតែពិនិត្យមើលភាពយុត្តិធម៌នៃតុលាការ ចាប់តាំងពីដើមដំបូងនៃនីតិវិធីរហូតដល់ចុងបញ្ចប់នៃនីតិវិធី គឺត្រូវត្រួតពិនិត្យតាំងពីមុនពេលជំរះក្តី នីតិវិធីនៅពេលជំរះក្តី និងនៅក្រោយពេលជំរះក្តីផងដែរ ។ ការជំនុំជំរះក្តីដែលនឹងលើកយកមកពិភាក្សានៅទីនេះ គឺសំដៅទៅលើតែការជំនុំជំរះរឿងក្តីព្រហ្មទណ្ឌ ដែលមានចែងនៅក្នុងច្បាប់កម្ពុជាស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៩៣ ដែលកំពុងអនុវត្តជាធរមាន នៅក្នុងប្រព័ន្ធតុលាការកម្ពុជាសព្វថ្ងៃចំពោះ រឿងក្តី ដូចជា ចោរកម្ម បទប្លន់ ឬឃាដកម្ម ជាដើម ។ នីតិវិធីព្រហ្មទណ្ឌនេះ អាចនឹងត្រូវយកទៅអនុវត្តនៅក្នុងដំណើរការនៃតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដោយយោងទៅតាមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ និងច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈពេលនៃកម្ពុជាប្រជាធិបតេយ្យ (ប្រកាសឱ្យប្រើថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤) ។

[១] មាត្រា៣១ កថាខ័ណ្ឌទី២ ឃ្លាទី១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

ប្រសិនបើមានចំនុចខ្វះចន្លោះនៅក្នុងច្បាប់នីតិវិធីក្នុងស្រុក នោះច្បាប់នីតិវិធីព្រហ្មទណ្ឌនៃច្បាប់អន្តរជាតិ ដូចជា តុលាការព្រហ្មទណ្ឌអន្តរជាតិ តុលាការពិសេសនៅរ៉្វាន់ដា និងតុលាការពិសេសនៅយូហ្គោស្លាវី ជាដើម នឹងត្រូវយកមកអនុវត្តបំពេញបន្ថែម ។

ប្រសិនបើការអនុវត្តន៍នីតិវិធីនៅក្នុងដំណាក់កាលណាមួយ ពុំមានលក្ខណៈត្រឹមត្រូវតាមគោលការណ៍យុត្តិធម៌ ការជំនុំជំរះទាំងមូលត្រូវចាត់ទុកថាពុំមានយុត្តិធម៌ ។ ភាគីដែលខូចប្រយោជន៍ អាចធ្វើការប្តឹងជំទាស់ ឬបដិសេធសេចក្តីសំរេច ឬប្តឹងពីមន្ត្រីតុលាការ ។

## I) គោលការណ៍សំខាន់ៗក្នុងដំណើរការជំនុំជំរះក្តី

ដំណើរការជំនុំជំរះក្តី គឺជាដំណាក់កាលមួយដែលមានចាប់តាំងពី ពេលដាក់ពាក្យបណ្តឹង ការស៊ើបអង្កេត ការជំនុំជំរះ ការចេញសាលក្រម ការអនុវត្តសាលក្រមរបស់តុលាការ និងមានសិទ្ធិប្តឹងឧទ្ធរណ៍ទៀតរហូតដល់ចប់សព្វគ្រប់ ។

ជាដំណាក់កាលមួយដែលព្រះរាជអាជ្ញាទើបតែទទួលបានពាក្យបណ្តឹង និងពិនិត្យមើលលើឯកសារនានា ដែលទទួលបាន ក្នុងករណីដែលពុំមានឯកសារគ្រប់គ្រាន់ទេ ព្រះរាជអាជ្ញាអាចដាក់បញ្ជាឱ្យមានការស៊ើបអង្កេត បន្ថែមទៀតដោយមានជំនួយពីចៅក្រមស៊ើបអង្កេត ពីព្រោះនៅក្នុងរឿងក្តីព្រហ្មទណ្ឌតុលាការដើរតួនាទីយ៉ាងសកម្មក្នុងការស្រាវជ្រាវស្វែងរកភស្តុតាង ដើម្បីដាក់បន្ទុក និងដោះបន្ទុក ចំពោះជនជាប់ចោទ។ នៅគ្រប់តំណាក់កាលនីតិវិធី ជាពិសេសការស្វែងរកឯកសារនានា ភាគីមិនអាចជៀសផុតពីការប្រាស្រ័យទាក់ទងជាមួយនឹងព្រះរាជអាជ្ញា បុគ្គលិកតុលាការនានា មេធាវី និងជាមួយភាគីម្ខាងទៀតនោះទេ ។ ហេតុដូច្នេះហើយ ភាគីទាំងពីរក៏ត្រូវតែទទួលបាននូវឱកាសក្នុងការទំនាក់ទំនងនេះ ឱ្យបានស្មើភាពគ្នាក្នុងការប្រើសិទ្ធិ និងដោយមានសុវត្ថិភាព ។

### ១) ការប្រាស្រ័យទាក់ទងដោយយុត្តិធម៌

ដើម្បីឱ្យសេចក្តីសំរេចរបស់ចៅក្រមអាចត្រូវបានកំណត់ថា "យុត្តិធម៌" គឺភាគីវិវាទទាំងពីរត្រូវទទួលបាននូវឱកាសស្មើគ្នា ដើម្បីបង្ហាញព័ត៌មានអំពី អង្គហេតុ ភស្តុតាង និងសាក្សីរបស់ខ្លួន តាមផ្លូវច្បាប់ជូនទៅចៅក្រម ។ ការបង្ហាញបែបនេះ អាចមានឥទ្ធិពលលើដំណើរការធ្វើសេចក្តីសំរេច របស់ចៅក្រមទៅលើរឿងក្តីរបស់ខ្លួន ។ ភាគីនីមួយៗ ត្រូវការព័ត៌មានទាំងអស់ដែលទាក់ទងនឹងរឿងក្តីរបស់ខ្លួនពីចៅក្រម ឬភាគីម្ខាងទៀត ដើម្បីធ្វើការបង្ហាញឱ្យបានសមស្របនឹងត្រៀមរៀបចំការពារខ្លួនជាមុននៅពេលបើកសវនាការ ។ ដូចគ្នានេះដែរ ភាគីនេះ ត្រូវតែផ្តល់ព័ត៌មានរបស់ខ្លួនទៅឱ្យចៅក្រម និងភាគីម្ខាងទៀតផងដែរ ។

ជាគោលការណ៍ ជនជាប់ចោទ ក៏មានសិទ្ធិស្មើគ្នានៅក្នុងការសាកសួរសាក្សីនៃភាគីម្ខាងទៀត ឬការសួរព័ត៌មានដែលពាក់ព័ន្ធអំពីភាគីម្ខាងទៀត និងសិទ្ធិស្នើសុំឱ្យមានការស្វែងរកភស្តុតាងផ្សេងៗ ដើម្បីការពារខ្លួន[២] ។

[២] មាត្រា១៤ កថាខ័ណ្ឌទី៣ ចំនុច (ង) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)

## ក- សិទ្ធិទទួលព័ត៌មាន

ភាគីក្តីទាំងសងខាង ឬភាគីទាំងអស់ដែលទាក់ទងនៅក្នុងរឿងក្តី (ជនជាប់ចោទ សាក្សី និងព្រះរាជអាជ្ញា) មានសិទ្ធិនៅក្នុងការទទួលព័ត៌មានស្មើគ្នាអំពី ការពិតដែលពាក់ព័ន្ធ ។ ចៅក្រម ត្រូវតែផ្តល់ឱ្យភាគីទាំងពីរនូវលទ្ធភាពដូចគ្នាក្នុងការទទួលដឹងពីអង្គហេតុ និងឯកសារនានា ហើយប្រាប់ពួកគេអំពីអង្គហេតុទាំងអស់ មតិយោបល់ អំណះអំណាង និងភស្តុតាង ដែលគេបានទទួលពីភាគីម្ខាងទៀត ឬដែលគេបានលើកឡើងដោយខ្លួនឯង និងភស្តុតាងដែលត្រូវបានរកឃើញថ្មីៗទៀត[៣] ។

ម្យ៉ាងទៀត ជនជាប់ចោទ មានសិទ្ធិទាមទារឱ្យគេប្រាប់ខ្លួនឱ្យដឹងភ្លាមៗនូវហេតុផល និងប្រភេទនៃបទល្មើសដែលគេចោទមកលើខ្លួន ឬប្រាប់ពីហេតុផលនៃការផ្តន្ទាទោស ដោយការប្រាប់នេះត្រូវតែនិយាយជាភាសាដែលសាមីខ្លួនជនជាប់ចោទអាចស្តាប់បាន[៤] ។

សិទ្ធិទទួលព័ត៌មាននេះ គឺជាសិទ្ធិមួយសំខាន់ណាស់ដែលតុលាការត្រូវផ្តល់ឱ្យជនជាប់ចោទ ដើម្បីឱ្យគាត់មានឱកាសគ្រប់គ្រាន់ និងរយៈពេលសមរម្យ នៅមុនពេលចូលរួមសវនាការក្នុងការពិនិត្យមើលលើការចោទប្រកាន់ និងរៀបចំឯកសារអំណះអំណាងការពារខ្លួននៅចំពោះមុខតុលាការ ។

ដូចនេះ តុលាការ ត្រូវតែបង្កលក្ខណៈងាយស្រួលដល់អ្នកចូលរួមក្នុងការទទួលបាននូវព័ត៌មាន ហើយក៏ត្រូវធានាឱ្យបាននូវការផ្តល់ឱ្យជនគ្រប់រូបនូវសិទ្ធិទទួលព័ត៌មាននេះផងដែរ ។

**ឧទាហរណ៍:**

ប្រសិនបើ ពូ មឹង ត្រូវបានគេចោទប្រកាន់ពីបទល្មើសណាមួយ ពូ មឹង អាចធ្វើសំណើដោយខ្លួនឯង ឬដោយមានជំនួយពីមេធាវី ដាក់ជូនព្រះរាជអាជ្ញាដើម្បីសុំមើលរាល់ឯកសារទាំងឡាយដែល ពាក់ព័ន្ធនឹងរឿងក្តីរបស់ ពូ មឹង ដូចជា កំណត់ហេតុដែលធ្វើដោយប៉ូលីស ឬភស្តុតាង និងឯកសារផ្សេងៗ ដែលផ្តល់ដោយដើមចោទ ។

## ខ- សិទ្ធិផ្តល់ព័ត៌មាន

ជនជាប់ចោទ ត្រូវផ្តល់ឱកាសស្មើគ្នា និងសិទ្ធិដូចគ្នា នៅក្នុងការបញ្ចេញមតិ បង្ហាញភស្តុតាង និងសាកសួរពីអង្គហេតុពីភាគីម្ខាងទៀត ។ ដូចជា ការទាមទាររកភស្តុតាងបន្ថែមដើម្បីជួយសំរាលទោស ឬរកសាក្សីការពារការសួរដេញដោលលើសាក្សីនៃភាគីបដិបក្ខ ។

នៅតំណាក់កាលស៊ើបអង្កេត ចៅក្រមស៊ើបអង្កេតអាចកោះហៅសាក្សីមកសាកសួរផ្ទាល់នៅការិយាល័យរបស់ខ្លួន ដោយចេញជាដីកាកោះដើម្បីជូនដំណឹងជាមុនដល់សាក្សី[៥] ។

សាក្សីត្រូវតែចូលខ្លួនទៅតាមការអញ្ជើញ ក្រោយពីបានទទួលលិខិតអញ្ជើញ បើសាក្សីមិនបានមកចំពោះមុខចៅក្រម សាក្សីត្រូវបញ្ជាក់ហេតុផលឱ្យបានសមស្រប ដូចជា ដោយហេតុតែមានការចាំបាច់ ឈឺ ឬមិនអាចធ្វើដំណើរបាន។

---

[៣] មាត្រា១១០ និង៧៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

[៤] មាត្រា៩ កថាខ័ណ្ឌទី២ និងមាត្រា១៤ កថាខ័ណ្ឌទី ៣ ចំនុច (ក) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(ICCPR)

[៥] មាត្រា៨១ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

នៅក្នុងករណីនេះ ចៅក្រមដោយមានក្រឡាបញ្ជីអមផង អាចអញ្ជើញទៅកាន់ទីលំនៅរបស់សាក្សី ដើម្បីស្តាប់ និង កត់យកចំលើយរបស់សាក្សី ។

### គ- សិទ្ធិគាំទ្រការប្រាស្រ័យទាក់ទង

នៅដំណាក់ការស៊ើបអង្កេត ចៅក្រមស៊ើបអង្កេតមានតួនាទីក្នុងការធានានូវការប្រាស្រ័យទាក់ទង រវាងភាគីក្តីទាំងសងខាង ឱ្យមានលក្ខណៈរលូន ដោយគោរព ឬអនុវត្តសិទ្ធិស្មើគ្នារវាងភាគី នៅក្នុងការរកអ្នកបកប្រែ (សំរាប់អ្នក គថ្លង់) អ្នកជំនាញ និងមេធាវី (ជំនួយផ្នែកច្បាប់) ។ សិទ្ធិទាំងអស់នេះ ត្រូវផ្តល់ឱ្យនៅពេលសវនាការកាត់ក្តី ក៏ដូចជានៅតំណាក់កាលមុនការកាត់ក្តី ដើម្បីជាការត្រៀមរៀបចំលក្ខណៈចូលសវនាការ ឬ ការការពារ ។
**ឧទាហរណ៍:** ការប្រាស្រ័យទាក់ទងដោយសេរី រវាងជនជាប់ចោទ ជាមួយមេធាវីការពារ [៦] ។

**លក្ខខណ្ឌក្នុងការទទួលបាននូវជំនួយផ្នែកច្បាប់** [៧]

- ជនរងគ្រោះជាអនីតិជនគ្មានទីពឹង
- ជនជាប់ចោទជាអនីតិជនគ្មានទីពឹង, ថ្លង់ មនុស្សខ្វាក់ ឬជនមានវិបត្តិស្មារតី
- គ្មានលទ្ធភាពអាចពឹងអ្នកជួយការពារខ្លួនបាន ។

## ២) ការប្រាស្រ័យទាក់ទងដោយសុវត្ថិភាព

លក្ខខណ្ឌបន្ថែមមួយសំរាប់ភាពយុត្តិធម៌ គឺដំណើរការត្រូវតែធ្វើជា**សាធារណៈ** និង**គ្មានការបង្ខិតបង្ខំ** ។ សវនាការរបស់តុលាការ ត្រូវបើកចំហរឱ្យសាធារណជនអាចចូលរួមដោយសេរី ដើម្បីសង្កេតការណ៍ និងពិនិត្យមើលថា តើភាគីទាំងពីរពិតជាត្រូវបានគេផ្តល់ឱ្យនូវឱកាសដូចគ្នា ឬក៏មានការរំលោភបំពាន បង្ខិតបង្ខំផ្សេងៗ ទៅលើសិទ្ធិរបស់បុគ្គលនីមួយៗដែរឬទេ ?

### ក- សិទ្ធិធ្វើការជំនុំជំរះជាសាធារណៈ

ជនជាប់ចោទ មានសិទ្ធិទទួលបាននូវការជំនុំជំរះជាសាធារណៈ ។

ជាទូទៅការជំនុំជំរះជាសាធារណៈ ជាការជំនុំជំរះដែលអនុញ្ញាតឱ្យមានការចូលរួមពីសាធារណជន និងអ្នកសារព័ត៌-មានដោយសេរី គឺថា ប្រជាពលរដ្ឋអាចចូលរួមស្តាប់ និងអង្គុយមើលការកាត់ក្តីនៅក្នុងតុលាការ ប៉ុន្តែ អាស្រ័យទៅលើទីកន្លែងទំនេររបស់តុលាការផងដែរ ហើយប្រជាពលរដ្ឋក៏ត្រូវមានកាតព្វកិច្ចគោរពបទបញ្ជាផ្ទៃក្នុងនៃសវនាការរបស់តុលាការដែរ ។ ម្យ៉ាងទៀត នៅក្រោយពេលកាត់ក្តីសាលក្រម ត្រូវផ្សព្វផ្សាយឱ្យសាធារណជនបានដឹងឮ បានន័យថានៅចុងបញ្ចប់នៃសវនាការ ចៅក្រមត្រូវអានសាលក្រម ប្រកាសឱ្យសាធារណជនដែលចូលរួមទាំងអស់ បានយល់ដឹងអំពីការសំរេចរបស់តុលាការ [៨] ។

---
[៦] មាត្រា៨០ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ
[៧] មាត្រា៧៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ
[៨] មាត្រា១៤២ និង១៤៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

ប៉ុន្តែ នៅក្នុងរឿងក្តីមួយចំនួន ការជំនុំជំរះ អាចមិនត្រូវបើកទូលាយជាសាធារណៈ ប្រសិនបើ គេយល់ឃើញថា អាចមានការប៉ះពាល់ដល់សីលធម៌ ឬសណ្តាប់ធ្នាប់សាធារណៈ ដូចជា រឿងក្តីលែងលះ ឬក៏រំលោភ ប៉ុន្តែសាលក្រម នៅតែប្រកាសជាសាធារណៈ [៩] ។

### ៩- សិទ្ធិមិនត្រូវបានគេបង្ខិតបង្ខំ

ការបង្ខិតបង្ខំចំពោះភាគីមួយ នៃភាគីទាំងពីរនេះ អាចមានការប៉ះពាល់ដល់ដំណើរការ នៃការស្វែងរកដំណោះស្រាយ "ដ៏យុត្តិធម៌" មួយ។ ពីព្រោះថា ដំណោះស្រាយដ៏យុត្តិធម៌ ត្រូវពឹងផ្អែកលើព័ត៌មានដែលមានលក្ខណៈពិតប្រាកដ និងមិនមានការបង្ខិតបង្ខំ (**ឧទាហរណ៍** តាមរយៈការធ្វើទារុណកម្ម ឬការបំភិតបំភ័យ)។ ព័ត៌មាន ដែលបានមកពីការបង្ខិតបង្ខំបែបនេះ មិនមានអំណោយផលល្អចំពោះជនរងគ្រោះ និងមិនបានទទួលនូវភាពយុត្តិធម៌ និងសច្ចៈធម៌ ដែលភាគីក្នុងជម្លោះចង់បាន នៅពេលខ្លួនបានដាក់ពាក្យនៅតុលាការ។

ដូច្នេះ ដំណើរការជំនុំជំរះក្តីប្រកបដោយលក្ខណៈយុត្តិធម៌ ត្រូវតែធានានូវសិទ្ធិមួយចំនួនរបស់ជនជាប់ចោទ គឺ សិទ្ធិមិនត្រូវបានគេៈ

- **គំរាមកំហែង ធ្វើបាប ធ្វើទារុណកម្ម**
- បង្ខិតបង្ខំឱ្យ**ឆ្លើយសារភាព** ឬ **ការសារភាពដាក់កំហុសខ្លួនឯង**
- កាត់ទោសដោយផ្អែកលើ **ភស្តុតាងដែលបានពីការធ្វើទារុណកម្ម ឬភស្តុតាងមិនពិតប្រាកដ**

ការទទួលសារភាព ឬចំលើយរបស់ជនជាប់ចោទដែលកើតឡើងពីការធ្វើបាប ធ្វើទារុណកម្ម ឬបង្ខិតបង្ខំតាមផ្លូវចិត្ត មិនអាចទុកជាភស្តុតាងនៃពិរុទ្ធភាពទេ [១០] ។

ចំពោះជនណាដែលគំរាមកំហែង ឬគៀបសង្កត់សាក្សី ក៏ត្រូវតែទទួលទោសទៅតាមច្បាប់ដែរ [១១] ។

**ឧទាហរណ៍ៈ**

ប្រសិនបើអ្នកត្រូវគេចោទប្រកាន់ និងឃុំខ្លួន រួចហើយគេបង្ខំឱ្យអ្នកសារភាពដោយបានធ្វើទារុណកម្ម ឬ វាយធ្វើបាប នោះនៅពេលសវនាការ នៅចំពោះមុខចៅក្រម អ្នកអាចស្នើឱ្យមេធាវីរបស់អ្នករៀបចំសុំណុំរឿងថ្មី ដើម្បីប្តឹងនឹងបុគ្គលដែលបានធ្វើបាបអ្នក ឬក៏អ្នកអាចប្តឹងបដិសេធ សុពលភាពនៃចំលើយសារភាពរបស់អ្នក ។

## ៣) ថេរៈវេលានៃនីតិវិធី

នៅក្នុងពេលជំនុំជំរះ (សវនាការ) ថេរៈវេលានៃនីតិវិធីរឿងក្តីដោយយុត្តិធម៌ ក៏ជាកត្តាដ៏សំខាន់បំផុតមួយ ដែលត្រូវពិចារណា នៅពេលនិយាយអំពីការរៀបចំនីតិវិធី "ដោយយុត្តិធម៌" នោះ ។ ថេរៈវេលានៃនីតិវិធីរឿងក្តីដោយ យុត្តិធម៌ មិនត្រូវលឿនពេក ហើយក៏មិនត្រូវយឺតពេកដែរ [១២] ។ ប្រសិនបើ ជំហានទីមួយៗនៃនីតិវិធី ដើម្បីស្វែងរកយុត្តិធម៌ ត្រូវបានចាត់ឡើងលឿនពេក អាចកាត់បន្ថយនូវសិទ្ធិ និងឱកាសសំរាប់ភាគីជម្លោះ ដោយសារពុំមានពេលវេលាគ្រប់គ្រាន់ ដើម្បីទទួល ផ្តល់ និង ពិនិត្យមើលព័ត៌មាន ហើយនឹងរៀបចំឯកសារសំអាងជូនទៅតុលាការ ។

---

[៩] មាត្រា១៤ កថាខ័ណ្ឌទី១ (ICCPR) និង មាត្រា ១២៩ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

[១០] មាត្រា៣៨ កថាខ័ណ្ឌទី៥ នៃរដ្ឋធម្មនុញ្ញ, មាត្រា២៤ កថាខ័ណ្ឌទី៣ ឃ្លាទី២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ហើយនិងមាត្រា១៤ វាក្យខ័ណ្ឌទី៣ ចំនុច ឆ នៃ ICCPR

[១១] មាត្រា៥៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

[១២] មាត្រា៩ កថាខ័ណ្ឌទី២ និង៣ និងមាត្រា១៤ កថាខ័ណ្ឌទី១ និង៣ ចំនុច (ក) (ខ) (គ) នៃ ICCPR

ផ្ទុយទៅវិញ ប្រសិនបើនីតិវិធីនោះយឺតយូរពេក ហើយត្រូវបានពន្យារពេលដោយមិនសមហេតុផលនោះ ក៏អាចផ្តល់ផលវិបាកចំពោះភាគីក្នុងជម្លោះដែរ ។

ដើម្បីធានានូវថេរៈវេលាសមស្របមួយសំរាប់ដំណើរការនីតិវិធី គេត្រូវការពារ និងធានាដល់សិទ្ធិរបស់ភាគី ដែលពាក់ព័ន្ធក្នុងរឿងក្តី ដូចជា នៅក្នុងរឿងក្តីព្រហ្មទណ្ឌ សិទ្ធិរបស់ជនជាប់ចោទ និងសិទ្ធិរបស់ជនរងគ្រោះ ឬសាក្សី មិនត្រូវបានរំលោភបំពានដោយអំណាច ឬអំពើមួយណាឡើយ ។

ការជំនុំជំរះត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ និងមានការការពារឱ្យបានត្រឹមត្រូវចំពោះសាក្សី និងជនរងគ្រោះ ។

ឧទាហរណ៏:

- ការឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្ន អាចធ្វើទៅបានទាល់តែមានការសំរេចរបស់ចៅក្រម ដោយមានសំណើពីព្រះរាជអាជ្ញា ។ រយៈពេលឃុំឃាំងជាបណ្តោះអាសន្ន ទោះស្ថិតក្នុងករណីណាក៏ដោយ មិនត្រូវឱ្យហួសពី ៤ខែទេ។ ប៉ុន្តែតាមការសំរេចដែលមានចែងនូវមូលហេតុរបស់ ចៅក្រម រយៈពេលនេះអាចបន្តដល់ ៦ខែ ប្រសិនបើមានការចាំបាច់សំរាប់ធ្វើការស៊ើបអង្កេត[១៣] ។

- ដើម្បីធានាការអនុវត្តន៏ច្បាប់ឱ្យបានទាន់ពេលវេលា និងមិនរអាក់រអួល ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវជ្រើសតាំងចៅក្រមជំរះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញា ឱ្យជំនួសចៅក្រមជំរះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាណាដែលបដិសេធមិនចូលរួមអង្គជំនុំជំរះ ។

ការជំនុំជំរះ មិនត្រូវប្រព្រឹត្តលឿនពេកទេ ។ ចៅក្រមជំនុំជំរះ ត្រូវបង្កលក្ខណៈឱ្យជនជាប់ចោទមានសិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់នៅក្នុងការនិយាយ ឬបញ្ចេញមតិ នៅពេលសវនាការ សិទ្ធិរកអ្នកជំនួយផ្នែកភាសា និងជំនួយផ្នែកច្បាប់ ។

## ៤) ភាពយុត្តិធម៌នៃការកាត់សេចក្តី

### ក- គោលការណ៏ឯករាជ្យភាពនៃចៅក្រម

ការជំនុំជំរះក្តី ក៏ត្រូវតែគោរពផងដែរ នូវ "គោលការណ៏ឯករាជ្យភាពនៃចៅក្រម" ។

- ចៅក្រម ត្រូវតែជាបុគ្គលដែលឯករាជ្យ និងមិនលំអៀង (លំអៀងទៅរកភាគីតែម្ខាង) នៅក្នុងការងារជំនុំជំរះក្តី ដោយមិនទទួលនូវឥទ្ធិពលពីថ្នាក់លើ ឬបុគ្គលណាមួយឡើយ[១៤]
- ចៅក្រមត្រូវជំនុំជំរះក្តីប្រកបដោយអនាគតិពេញលេញ (មិនលំអៀង) ដោយផ្អែកលើអង្គហេតុនិងអង្គច្បាប់
- ចៅក្រម មិនត្រូវទទួលការគំរាមកំហែង បង្ខិតបង្ខំ ពីបុគ្គលណាទេ ។

[១៣] មាត្រា ១៤ កថាខ័ណ្ឌទី ៤ នៃច្បាប់ស្តីពីព្រហ្មទណ្ឌអន្តរកាល

[៧៤] មាត្រា១ នៃច្បាប់ស្តីពីព្រហ្មទណ្ឌអន្តរកាល និងមាត្រា១២៨ កថាខ័ណ្ឌទី១ និង២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

### ខ- គោលការណ៍នីត្យានុកូលភាព ( ច្បាប់)

ការចោទប្រកាន់បុគ្គលណាម្នាក់អំពីបទល្មើសអ្វីមួយ គឺត្រូវធ្វើឡើងដោយគោរពដល់គោលការណ៍ **"គ្មានបទល្មើសទេ បើសិនជាច្បាប់មិនមានចែងពីបទល្មើសនោះ"**[១៥] (Nulla poena sine lege) បានន័យថា គេមិនអាចធ្វើការចោទប្រកាន់ អំពីបទល្មើសណាមួយដែលមិនបានកំណត់ ឬចែងជាលាយលក្ខណ៍អក្សរនៅក្នុងបទដ្ឋានច្បាប់ហើយ បើច្បាប់មិនបានចែងអំពីអំពើល្មើសនោះ បានន័យថា ពុំមានបទល្មើសបែបនោះទេ ។ តុលាការក៏មិនអាចដាក់ទណ្ឌកម្ម (ទោស) ទៅលើជននោះបានដែរ បើច្បាប់មិនបានកំនត់ថាមានទណ្ឌកម្ម (ទោស) ចំពោះអំពើនោះ។

ច្បាប់ដែលមានចែងអំពីបទល្មើសទាំងនោះ គឺសំដៅទៅលើទាំងច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដែលមានអនុភាពអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដោយឡែកចំពោះច្បាប់អន្តរជាតិ ត្រូវតែមានការផ្តល់សច្ចាប័នដោយរដ្ឋសភាជាមុនសិន។

### គ- គោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់

គោលការណ៍ស្មើភាពនៃពលរដ្ឋទាំងអស់ចំពោះមុខច្បាប់ តំរូវឱ្យមានការវិនិច្ឆ័យទោសចំពោះជនល្មើសដោយគ្មានករណីលើកលែងទោសឡើយ។

### ឃ- គោលការណ៍សច្ចាធារណ៍នៃនិរទោស

មានន័យថា គ្រប់ជនដែលគេសង្ស័យ គ្រប់ពិរុទ្ធជន គ្រប់ជនជាប់ចោទ ត្រូវសន្មតជាមុនថា គ្មានកំហុស បើមិនទាន់មានការប្រកាសពីតុលាការថា មានពិរុទ្ធ[១៦] បានន័យថា ជនសង្ស័យ ពិរុទ្ធជន ជនជាប់ចោទ ដរាបណាគ្មានភស្តុតាងគ្រប់គ្រាន់ បុគ្គលនោះ ត្រូវបានរួចផុតពីការចោទប្រកាន់ ។

ដូចគ្នានេះដែរ គោលការណ៍ **"អត្ថប្រយោជន៍នៃវិមតិសង្ស័យ"**[១៧] ("in dubio pro reo") មានន័យថា ក្នុងករណី ដែលព្រះរាជអាជ្ញាផ្តល់នូវភស្តុតាងចោទប្រកាន់មួយចំនួន ដែលមានលក្ខណៈមិនគ្រប់គ្រាន់ក្នុងការបញ្ជាក់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ចៅក្រមមិនអាចកាត់ឱ្យជននោះជាប់ទោសទេ ហើយត្រូវរួចផុតពីការចោទប្រកាន់ដោយចាត់ទុកថាគ្មានកំហុស[១៨] ។

## ៥) ភាពយុត្តិធម៌នៃសាលក្រម

សាលក្រម ត្រូវធ្វើឡើងដោយគ្មានការពន្យារពេលឡើយ។ ក្នុងករណីដែលមាន ការកាត់ទោសអនីតិជន ត្រូវធ្វើឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន[១៩] ។

---

[១៥] មាត្រា១៥ កថាខ័ណ្ឌទី១ នៃ ICCPR និង មាត្រា៣៨ កថាខ័ណ្ឌទី៧ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[១៦] មាត្រា២៥ នៃច្បាប់ស្តីពីព្រហ្មទណ្ឌអន្តរកាល

[១៧] មាត្រា៣៨ កថាខ័ណ្ឌទី៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[១៨] មាត្រា១៤ វាក្យខ័ណ្ឌទី២ ICCPR

[១៩] មាត្រា១០ (ខ) ICCPR និង មាត្រា១១៤ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

សាលក្រមមួយរបស់តុលាការ ត្រូវតែមានតុល្យភាព និងមានភាពយុត្តិធម៌ ។ សាលក្រម ត្រូវចង្អុលអំពីអង្គហេតុ ដែលត្រូវចោទប្រកាន់ អំពើរបស់ជនជាប់ចោទ សាក្សី ឬភស្តុតាង ដែលត្រូវចាត់ទុកថា ត្រឹមត្រូវ ហើយមានចែង មូលហេតុច្បាស់លាស់ ដែលនាំឱ្យឈានទៅដល់ការវិនិច្ឆ័យដល់អង្គសេចក្តី[២០] ។ សាលក្រមនេះ មិនត្រូវដាក់បន្ទុក វិសមាមាត្រទៅលើភាគីដែលត្រូវបានកាត់ឱ្យជាប់ទោស ឬករណីយកិច្ចណាដែលមិនអាចបំពេញបានឡើយ ។ ក្នុងន័យនេះ ជាប្រការមិន "**យុត្តិធម៌**" ទេ ប្រសិនបើសាលក្រមមួយដាក់ទណ្ឌកម្មជាលើកទីពីរ (ពីរដង) ចំពោះបទឧក្រិដ្ឋតែមួយ ឬ ប្រសិនបើ នៅពេលក្រោយមកសាលក្រមនេះអនុវត្តច្បាប់ព្រហ្មទណ្ឌថ្មីទៅលើបទល្មើសដែលបានវិនិច្ឆ័យទោសរួចហើយ ។ ម្យ៉ាងទៀត សាលក្រម ក៏មិនត្រូវដាក់ទណ្ឌកម្មហួសហេតុលើសពីការកំនត់របស់ច្បាប់ និងគោលការណ៍របស់ ច្បាប់ឡើយ[២១] ។

- **គោលការណ៍អប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ**

ជាគោលការណ៍នៃនីតិព្រហ្មទណ្ឌ មិនមានអនុភាពជាប្រតិសកម្មឡើយ ។ "**ការហាមឃាត់ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ**" បានន័យថា ចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្នុងច្បាប់ចាស់ ត្រូវយកច្បាប់ចាស់មកអនុវត្ត គេមិនអាចនឹងយកច្បាប់ថ្មីមកអនុវត្តបានទេ ។ ប៉ុន្តែ វាអាចមាន នីតិប្រតិសកម្មបាន ចំពោះការដាក់ទណ្ឌកម្ម (ទោស) ទៅលើបទល្មើសដូចគ្នាដែលមានចែងទាំងនៅក្នុងច្បាប់ចាស់ និង ច្បាប់ថ្មីនោះ ដោយសារច្បាប់ថ្មីមានទណ្ឌកម្មស្រាលជាងច្បាប់ចាស់ ហើយម្យ៉ាងទៀតជនល្មើសនោះ មិនទាន់បាន ជំរះសេចក្តីពីតុលាការនៅឡើយ ។

**ឧទាហរណ៍:**

គេមិនអាចយកច្បាប់ព្រហ្មទណ្ឌអន្តរកាលឆ្នាំ១៩៩២ ទៅអនុវត្តនៅក្នុងការកាត់ទោសចំពោះបទឧក្រិដ្ឋទាំងឡាយ ដែលបានប្រព្រឹត្តនៅចន្លោះ ថ្ងៃទី១៧ មេសា ១៩៧៥ ដល់ ថ្ងៃទី៦ មករា ១៩៧៩ បានទេ គឺតុលាការត្រូវអនុវត្ត ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ ។ ប៉ុន្តែ មានករណីលើកលែងដែលថា ចៅក្រម អាចអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ ១៩៩២ អនុវត្តទៅលើបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងបំពានច្បាប់ ឆ្នាំ១៩៥៦ បានដោយសារតែការដាក់ទណ្ឌកម្ម (ដាក់ទោស) មានស្ថានសំរាលទោសស្រាលជាងច្បាប់ព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ ។

គូភាគីទាំងពីរ មានសិទ្ធិដាក់ពាក្យបណ្តឹងឧទ្ធរណ៍នៅក្នុងរយៈពេល ២ខែ បន្ទាប់ពីថ្ងៃចេញសាលក្រមចំពោះមុខ បើសិនជាមិនឯកភាពលើការសំរេចរបស់ចៅក្រម ។

## II) ដំណោះស្រាយចំពោះការធ្វើផ្ទុយពីគោលការណ៍កាត់ក្តីដោយយុត្តិធម៌

នៅក្នុងករណីព្រហ្មទណ្ឌ ចៅក្រម ព្រះរាជអាជ្ញា និងមេធាវីរបស់ជនជាប់ចោទ ត្រូវតែធានាថា គ្មានការរំលោភលើគោលការណ៍កាត់ក្តីដោយយុត្តិធម៌ជាដាច់ខាត ។ នេះជាភារកិច្ចទទួលខុសត្រូវមួយ ដើម្បីធានានូវនីតិវិធីកាត់ក្តីដោយយុត្តិធម៌។ ភាគីពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់តាមដាននីតិវិធីនៃតុលាការ និងស្នើសុំឱ្យអនុវត្តន៍ទៅតាមនីតិវិធីច្បាប់

[២០] មាត្រា២៦ នៃច្បាប់ស្តីពីព្រហ្មទណ្ឌអន្តរកាល និងមាត្រា១៤៤ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

[២១] មាត្រា១៥ កថាខណ្ឌទី១ ICCPR

នៅពេលដែលឃើញថា សិទ្ធិរបស់ភាគីមួយមិនត្រូវបានគោរពដោយចៅក្រម ដោយព្រះរាជអាជ្ញា ឬដោយភាគីមួយទៀត។ ការមិនគោរពសិទ្ធិទាំងនោះ អាចលេចចេញមកជារូបភាពផ្សេងៗគ្នា ដូចជា:

១) ចៅក្រមមានចិត្តលំអៀង ស៊ីសំណូក អគតិ នៅក្នុងការវិនិច្ឆ័យរឿងក្ដី
២) ភាគីម្ខាងបដិសេធសិទ្ធិរបស់ភាគីម្ខាងទៀត មិនឱ្យពិនិត្យមើលឯកសាររបស់ខ្លួន
៣) តុលាការទទួលស្គាល់សុពលភាពនៃការឆ្លើយសារភាពពីពិរុទ្ធភាពរបស់ចុងចោទ ដែលបានមកពីការធ្វើទារុណកម្ម
៤) អត្ថបទនៃសាលក្រមមិនមានបញ្ជាក់ហេតុផល

នៅក្នុងករណីដូចបានជំរាបជូនខាងលើព្រះរាជអាជ្ញានិងភាគីដែលមានមេធាវីការពារមានសិទ្ធិទាមទារឱ្យចៅក្រមកែសំរួលនីតិវិធីរបស់ខ្លួន ឱ្យស្របទៅនឹងនីតិវិធីច្បាប់ ឬមានសិទ្ធិប្ដឹងបដិសេធតាមចំណុចដែលបានរៀបរាប់ខាងលើ ។ ក្រលាបញ្ជី ត្រូវកត់ត្រាជាលាយលក្ខណ៍អក្សរនូវការទាមទារ ឬការបដិសេធទាំងនេះ នៅក្នុងកំណត់ហេតុជាផ្លូវការ នៃនីតិវិធីរឿងក្ដី ។ ក្នុងបណ្ដឹងឧទ្ធរណ៍ ភាគីបណ្ដឹងមានសិទ្ធិសុំឱ្យសាលាឧទ្ធរណ៍ពិនិត្យ មើលពីកំហុសនីតិវិធីរបស់តុលាការដំបូង[២២] ។

ការប្ដឹងទាមទារពាក់ព័ន្ធនឹងកំហុសនីតិវិធី អាចធ្វើឡើងជា:

## ១) ការប្ដឹងជំទាស់: ការប្តឹងជិតចិត្ត:

បណ្ដឹងជិតចិត្ត គឺបណ្ដឹងដែលពាក់ព័ន្ធនឹងការសំរេចសាលក្រមរបស់ចៅក្រម ដោយសារភាគីនៃរឿងក្ដី ណាមួយមានការសង្ស័យទៅនឹងការកាត់ក្ដីរបស់ចៅក្រម។ បណ្ដឹងនេះ ត្រូវមានមូលហេតុច្បាស់លាស់អំពី ភាពលំអៀង ដែលបណ្ដាលឱ្យប៉ះពាល់ដល់សេចក្ដីសំរេចរបស់ចៅក្រម ។ ការប្ដឹងនេះ អាចមកពី[២៣]:

ក) ប្រពន្ធចៅក្រមមានផលប្រយោជន៍ផ្ទាល់ខ្លួនក្នុងរឿងក្ដី
ខ) ចៅក្រម ឬញាតិពន្ធ ឬបងប្អូនចៅក្រម ក្នុងនាមជាភាគីប្ដឹង
គ) គ្រួសាររបស់ចៅក្រមធ្លាប់មានទំនាស់ជាមួយភាគីម្ខាងទៀត
ឃ) ចៅក្រមធ្លាប់ធ្វើជាអាជ្ញាកណ្ដាល ឬសាក្សី ប៉ុន្តែមិនត្រូវគ្នា
ង) ជាអមិត្ត ឬ មិត្តស្និទស្នាល

ម្យ៉ាងទៀត គេអាចធ្វើបណ្ដឹងទៅក្រុមប្រឹក្សានៃអង្គចៅក្រម[២៤] ដែលមានតួនាទីដាក់ទោស ឬពិន័យចំពោះចៅក្រម និងព្រះរាជអាជ្ញា ទាំងឡាយណាដែលប្រព្រឹត្តផ្ទុយពីក្រមសីលធម៌វិជ្ជាជីវៈ ។

## ២) ការប្តឹងបដិសេធ ឬប្តឹងទាមទារ:

[២២] មាត្រា ១៦៣ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ
[២៣] មាត្រា ២៦២ នៃក្រមពិភាក្សារដ្ឋប្បវេណី ឆ្នាំ១៩៦២
[២៤] មាត្រា ១៣៤កថាខ័ណ្ឌទី ៣ និង ទី ៤

មេធាវី អាចប្តឹងបដិសេធចំពោះចំលើយដែលទទួលបានមកពីការធ្វើទារុណកម្មលើចុងចោទ ។ មេធាវីរបស់ជនជាប់ចោទ ត្រូវសុំទៅចៅក្រមឱ្យចាត់ទុកចំលើយនេះ ជាមោឃៈ (មិនយកជាការ) ។

បើសិន ភាគីម្ខាងមិនអនុញ្ញាតឱ្យគូក្តីរបស់ខ្លួន ពិនិត្យសំណុំរឿង មេធាវីអាចប្តឹងទាមទារឱ្យភាគីម្ខាងទៀត អនុវត្តទៅតាមនីតិវិធីដោយអាចមើលឯកសារទាំងនោះ ។

មេធាវីអាចប្តឹងទាមទារទៅតាមនីតិវិធី ដោយស្នើសុំឱ្យតុលាការកោះហៅសាក្សី និងមន្ត្រីនគរបាលមកបង្ហាញមុខឆ្លើយបំភ្លឺ និងសាកសួរព័ត៌បន្ថែម ។

អ្នកមានផលប្រយោជន៍ក្នុងរឿងក្តី អាចប្តឹងទាមទារឱ្យមានការពន្យល់ជាលាយលក្ខណ៍អក្សរពីហេតុផលនៃសាលក្រម ។

### ៣) បណ្តឹងជំទាស់ ឬការប្តឹងទាស់[២៥] :

បណ្តឹងជំទាស់ ឬបណ្តឹងទាស់ គឺជាបណ្តឹងតវ៉ារបស់ភាគីអវត្តមាន នៅពេលជំនុំជំរះក្នុងគោលបំណងឱ្យតុលាការសាមីដែលបានចេញសាលក្រម ឬសាលដីកា ឬសេចក្តីសំរេចកំបាំងមុខនេះ លើកយករឿងក្តី ដើម្បីធ្វើការជំនុំជំរះសារឡើងវិញ ចំពោះមុខខ្លួន ។ ភាគីអវត្តមាន មានសិទ្ធិប្តឹងទាស់ក្នុងរយៈពេល ១៥ថ្ងៃ គិតចាប់ពីថ្ងៃដែលខ្លួនទទួលបានដំណឹង អំពីសេចក្តីសំរេចកំបាំងមុខ ។

### ៤) ការប្តឹងឧទ្ធរណ៍[២៦] :

បណ្តឹងឧទ្ធរណ៍ គឺជាការប្តឹងតវ៉ារបស់ភាគីនៃរឿងក្តី ដែលមិនសុខចិត្តនឹងសាលក្រម ឬសេចក្តីសំរេចរបស់តុលាការជាន់ទាប ក្នុងគោលបំណងឱ្យសាលាឧទ្ធរណ៍ពិនិត្យឡើងវិញ អំពីអង្គហេតុ និងអង្គច្បាប់នៃរឿងក្តីរបស់ខ្លួន។ ភាគីចំពោះមុខ អាចមានសិទ្ធិប្តឹងឧទ្ធរណ៍រយៈពេល ២ខែ គិតចាប់ពីថ្ងៃប្រកាសសាលក្រម ឬ សេចក្តីសំរេច ។ រីឯភាគីកំបាំងមុខ អាចមានសិទ្ធិប្តឹងឧទ្ធរណ៍រយៈពេល ២ខែ គិតពីថ្ងៃផុតកំនត់ប្តឹងទាស់ក្នុងរយៈពេល ១៥ថ្ងៃ ។

### ៥) ការប្តឹងសើរើ[២៧] :

បណ្តឹងសើរើ គឺជាបណ្តឹងតវ៉ាមួយ មិនសុខចិត្តនឹងសាលក្រម ឬសាលដីកា ស្ថាពរហើយនោះ ។ មានតែតុលាការកំពូលទេ ដែលមានសមត្ថកិច្ចជំនុំជំរះលើបណ្តឹងសើរើនេះ ។

បណ្តឹងសើរើនេះ មិនអាចធ្វើបានចំពោះ សាលក្រម ឬសាលដីកាដែលសំរេចឱ្យរួចខ្លួននោះទេ ។

អ្នកដែលមានសិទ្ធិប្តឹងសុំឱ្យជំនុំជំរះសើរើបាន រួមមានៈ

- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

[២៥] មាត្រា ១១៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

[២៦] មាត្រា៧ នៃច្បាប់អំពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះនៃរដ្ឋកម្ពុជា និងមាត្រា១៥៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

[២៧] មាត្រា ២២៧ និង ២២៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ និង មាត្រា១៥ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពនៃសាលាជំរះក្តីនៃរដ្ឋកម្ពុជា ។

- ទណ្ឌិត ឬតំណាងពេញច្បាប់របស់ទណ្ឌិតក្នុងករណីទណ្ឌិតអសមត្ថភាព
- សហព័ទ្ធ ឪពុកម្តាយ កូនរបស់ទណ្ឌិត និយាយរួមជនដែលមានប្រយោជន៍ផ្នែកសំភារៈ ឬខាងផ្លូវចិត្ត កាលណាទណ្ឌិតនោះស្លាប់ ឬបាត់ខ្លួន ។